# សេចក្តីប្រកាសព័ត៌មាន
# ការប្រារព្ធទិវាអន្តរជាតិនារី ខួបលើកទី១១២
# ក្រោមប្រធានបទ «គាំពារស្ត្រី និងក្មេងស្រី ដើម្បីយុត្តិធម៌ទាំងអស់គ្នា»

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣

យើងខ្ញុំជាក្រុមអង្គការសង្គមស៊ីវិល ដូចជា សហជីព សហព័ន្ធសហជីព អង្គការ និងសមាគមដែលកំពុងធ្វើការងារដើម្បីលើកកម្ពស់សិទ្ធិស្ត្រី និងសមភាពយេនឌ័រនៅប្រទេសកម្ពុជា រួមមាន សហព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាសហព័ន្ធសហជីពកម្ពុជាសហព័ន្ធសហជីពកម្មករសំណង់និងព្រៃឈើកម្ពុជាសហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរសមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ បណ្តាញយុវជនកម្ពុជា អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស អង្គការសមាគមធាងត្នោត សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្សលីកាដូ អង្គការក្លាហាន និងអង្គការសមធម៌កម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជន និងអ្នកសារព័ត៌មានជាតិ និងអន្តរជាតិមេត្តាជ្រាបថា៖ យើងខ្ញុំទាំងអស់គ្នានឹងប្រារព្ធកម្មវិធីខួបលើកទី១១២ នៃទិវាអន្តរជាតិនារីក្រោមប្រធានបទ **«គាំពារស្ត្រីនិងក្មេងស្រី ដើម្បីយុត្តិធម៌ទាំងអស់គ្នា»**។

គោលបំណងនៃការប្រារព្ធកម្មវិធីនេះគឺដើម្បីរម្លឹកដល់ការតស៊ូ និងកិច្ចខិតខំប្រឹងប្រែងរបស់ស្ត្រី ក្មេងស្រី និងអ្នកការពារសិទ្ធិមនុស្សជាស្ត្រីនៅគ្រប់វិស័យ ក៏ដូចជាបង្ហាញដល់សាធារណជនឱ្យបានជ្រាបអំពីតម្រូវការ បញ្ហាប្រឈមរបស់ស្ត្រី និងក្មេងស្រី ព្រមទាំងស្នើឱ្យរដ្ឋាភិបាលដោះស្រាយនូវតម្រូវការចាំបាច់ ទុក្ខកង្វល់ពាក់ព័ន្ធនឹងប្រព័ន្ធគាំពារសង្គម និងភាពអយុត្តិធម៌សម្រាប់ស្ត្រី និងក្មេងស្រីរងគ្រោះ។

អាស្រ័យហេតុនេះ សូមសាធារណជនជ្រាបជាព័ត៌មាន និងចូលរួមជាមួយយើងខ្ញុំតាមលទ្ធភាពដែលអាចធ្វើទៅបានតាមកម្មវិធីដូចខាងក្រោម៖

- នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ យើងខ្ញុំនឹងចេញផ្សាយខិត្តប័ណ្ណរាប់ថ្ងៃថយក្រោយដើម្បីបង្ហាញកាលបរិច្ឆេទរំកិលជិតមកដល់ទិវាអន្តរជាតិនារី
- ចាប់ពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ ដល់ថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៣ យើងខ្ញុំនឹងចេញផ្សាយវីដេអូចំនួន៧ បន្តបន្ទាប់គ្នា ដែលក្នុងវីដេអូទាំង៧នោះ លើកឡើងនូវសំណើឱ្យមានការដោះស្រាយនូវបញ្ហាប្រឈមចំនួន១៧ ចំណុច តាមវិស័យនីមួយៗ។
- នៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០២៣ យើងខ្ញុំនឹងរៀបចំកម្មវិធីវិទ្យុពិភាក្សាលើប្រធានបទ៖ «**ការចូលរួមរបស់អង្គការសង្គមស៊ីវិលនៅក្នុងយុទ្ធនាការទិវាអន្តរជាតិនារីឆ្នាំ២០២៣**»។
- នៅថ្ងៃទី ៨ ខែមីនា ឆ្នាំ២០២៣ យើងខ្ញុំនឹងរៀបចំកម្មវិធីជួបជុំគ្នានៅទីលានប្រជាធិបតេយ្យ ដើម្បីប្រារព្ធទិវាអន្តរជាតិនារីក្រោមប្រធានបទ៖ «**គាំពារស្ត្រីនិងក្មេងស្រី ដើម្បីយុត្តិធម៌ទាំងអស់គ្នា**» ដែលមានអ្នកចូលរួមចំនួនប្រមាណ ៥០០ នាក់៕


**ព័ត៌មានបន្ថែម សូមទាក់ទង៖**

| | | | | |
|---|---|---|---|---|
| អ្នកស្រី អ៊ូ ទេពផល្លីន | អ្នកស្រី យ៉ាង សុភ័ណ្ឌ | អ្នកស្រី ចក់ សុភាព | អ្នកស្រី មាស សាអ៊ីម | លោក យុន ថារ៉ូ |
| ០១១ ៩៨៤ ៨៨៣ | ០១២ ៨៨០ ០៣៩ | ០១១ ៩៤៣ ២១៣ | ០៨៦ ៣៨២ ៦៦៦ | ០៩៣ ៥៥៦ ៦៧១ |